**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១០ សរណន**

# សារាចរណែនាំ

## ស្តីពី

## ការចូលរួមមរណទុក្ខសពលោកជំទាវ ញ៉ែម សឿន ជា ស៊ីម

ដើម្បីចូលរួមរំលែកមរណទុក្ខ ដោយក្តីសង្វេគរកទីបំផុតគ្មាន ចំពោះការបាត់បង់លោកជំទាវ ញ៉ែម សឿន ជា ស៊ីម ជាភរិយាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរព និងដែលជាវរៈស្ត្រីខ្មែរ មាតា និងជីដូនប្រកបដោយព្រហ្មវិហារធម៌ ដែលមួយជីវិតរបស់លោកជំទាវ ពោរពេញទៅដោយឆន្ទៈ មនសិការ បញ្ញាញាណ ហ៊ានធ្វើពលិកម្ម ដើម្បីបំរើឧត្តមប្រយោជន៍ប្រទេសជាតិ មាតុភូមិ និងប្រជាជនកម្ពុជា ជាទីស្នេហានៃយើង ដែលបានទទួលមរណភាព នាថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ២០០៩ វេលាម៉ោង ០៣:១៥ នាទីទៀបភ្លឺដោយរោគាពាធ រាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការណែនាំដូចតទៅ :

១-ប្រកាសថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៩ ជាថ្ងៃកាន់ទុក្ខ ជាផ្លូវការ ។

២-គ្រប់ក្រសួង ស្ថាប័ន សាលារៀន មន្ទីរពេទ្យរបស់រដ្ឋ ឯកជនទាំងអស់ និងមន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ គ្រប់ទីវត្តអារាម ព្រមទាំងប្រជាជនទូទាំងប្រទេស សូមបង្ហូតទង់ជាតិត្រឹមពាក់កណ្តាលដង នៅថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៩ ។

៣-គ្រប់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ ជាតិ និងឯកជនទាំងអស់ សូមផ្អាកការសំដែង និងការចាក់ផ្សាយនូវទស្សនីយភាពផ្សេងៗដែលមានលក្ខណៈសប្បាយគ្រឹកគគ្រេង នៅថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៩ ។

ទទួលបានសារាចរណែនាំនេះ គ្រប់អាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងជនរួមជាតិទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីជាកិច្ចចូលរួមមរណទុក្ខដ៏ក្រៀមក្រំបំផុតនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៩

**កន្លែងទទួល :**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- -គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -គ្រប់សាលារាជធានី ខេត្ត
- -ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន